# ស្ថានភាពអតិផរណានៅខែកញ្ញា ឆ្នាំ២០១៨

## ក/ អតិផរណាក្នុងប្រទេស

តាមប្រភពទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ (NIS) បានបង្ហាញថា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែកញ្ញា មានការកើនឡើង **០,៣%** ធៀបនឹងខែមុន និង **២,៦%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

ក្នុងខែកញ្ញា ឆ្នាំ២០១៨នេះ កំណើនសន្ទស្សន៍ថ្លៃទំនិញភាគច្រើនមានអត្រាប្រហែលគ្នាទៅនឹងខែសីហាកន្លងទៅ ក្នុងនោះសន្ទស្សន៍ថ្លៃក្រុមទំនិញអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងកើន ២,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន (២,៧% ក្នុងខែសីហា), ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់កើន ២,០% (១,៥% ក្នុងខែសីហា), សម្លៀកបំពាក់និងស្បែកជើងកើន ២,៧% (៣,៣% ក្នុងខែសីហា), និងភោជនីយដ្ឋានកើន ៦,០% (៥,៤% ក្នុងខែសីហា)។

**គិតត្រឹមខែកញ្ញា អតិផរណាមធ្យមប្រចាំឆ្នាំ (year average) មានអត្រា ២,៤% ទាបជាងអត្រាក្នុងខែដូចគ្នាឆ្នាំ ២០១៧ ដែលមានអត្រា ៣,៣%។** តាមការសង្កេត កំណើនទាបនៃអត្រាអតិផរណាមធ្យមប្រចាំឆ្នាំនេះ មួយផ្នែកគឺដោយសារការថមថយកំណើននៃសន្ទស្សន៍ថ្លៃក្រុមម្ហូបអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង (មេគុណ ៤៤,៨% នៃទំហំកន្ត្រកទំនិញសរុប) ដែលមានអត្រាកំណើនជាមធ្យម ២,៣% ទាបជាងឆ្នាំ២០១៧ ដែលមានអត្រា ៤,៤%។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **+០,៣** | **+២,៦** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +០,៣ | +២,៥ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +០,៦ | +២,០ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | +០,០ | +២,៧ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | +០,៦ | +១,៤ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | -១,១ | +០,១ |
| ៦-សុខាភិបាល | +០,២ | +១,៥ |
| ៧-ការដឹកជញ្ជូន | +១,៣ | +៣,៧ |
| ៨-គមនាគមន៍ | -០,២ | -១,០ |
| ៩-ការកំសាន្ត និងវប្បធម៌ | -០,៤ | +០,៦ |
| ១០-ការសិក្សា | -១,២ | -០,៤ |
| ១១-ភោជនីយដ្ឋាន | +០,៥ | +៦,០ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -០,៦ | +១,៧ |

| តារាង ២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៨ | | | ២០១៨ | | |
| | កក្កដា | សីហា | កញ្ញា | កក្កដា | សីហា | កញ្ញា |
| អង្ករ | 0,0 | +0,៩ | +0,១ | +២,១ | +២,៨ | +២,៧ |
| សាច់គោ | -0,៣ | +0,៤ | +0,២ | +៣,៤ | +២,៦ | +២,១ |
| សាច់មាន់ | +0,១ | +0,៥ | 0,0 | +២,៤ | +១,៨ | +២,0 |
| សាច់ទា | +0,៥ | -0,៥ | +0,១ | +២,0 | +0,១ | +១,៩ |
| សាច់ជ្រូក | -0,២ | +២,0 | +0,៥ | +១,៣ | +៣,0 | +៣,៤ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | -0,៨ | +0,៨ | +0,៥ | +៣,៨ | +៤,៦ | +៣,២ |
| ក្នុងនោះត្រីស្រស់ | -១,១ | +0,៨ | +0,៧ | +៣,៦ | +៤,៧ | +៣,២ |
| ផ្លែឈើ | -0,៩ | +0,២ | -0,៥ | +១,៨ | +២,៣ | +១,៧ |
| ផ្លែឈើស្រស់ | -១,២ | +0,៣ | -0,៧ | +១,៣ | +២,៣ | +១,៦ |
| បន្លែ | -0,៦ | +១,១ | +១,៥ | +២,៨ | +២,៨ | +៤,៣ |
| បន្លែជាស្លឹក | +0,៥ | +0,៥ | +១,៨ | +៥,៣ | +៥,0 | +៧,៥ |
| បន្លែជាផ្លែ | -១,៨ | +២,៣ | +២,៨ | +២,២ | +២,២ | +៥,៧ |

## ៦/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | | | |
|---|---|---|---|---|---|---|
| ប្រទេស | ២០១៧ | | | ២០១៨ | | |
| | កក្កដា | សីហា | កញ្ញា | កក្កដា | សីហា | កញ្ញា |
| ប្រទេសកម្ពុជា | 2.3 | 2.6 | 2.7 | 2.3 | 2.6 | 2.6 |
| ប្រទេសវៀតណាម | 2.5 | 3.4 | 3.4 | 4.5 | 4.0 | 4.0 |
| ប្រទេសថៃ | 0.2 | 0.3 | 0.9 | 1.5 | 1.6 | 1.3 |
| ប្រទេសម៉ាឡេស៊ី | 3.2 | 3.7 | 4.3 | 0.9 | 0.2 | 0.3 |
| ប្រទេសឥណ្ឌូនេស៊ី | 3.9 | 3.8 | 3.7 | 3.2 | 3.2 | 2.9 |
| ប្រទេសហ្វីលីពីន | 2.4 | 2.7 | 3.1 | 5.7 | 6.4 | 6.7 |
| ប្រទេសចិន | 1.4 | 1.8 | 1.6 | 2.1 | 2.3 | 2.5 |
| ប្រទេសកូរ៉េខាងត្បូង | 2.2 | 2.6 | 2.1 | 1.5 | 1.4 | 1.9 |
| ប្រទេសជប៉ុន | 0.4 | 0.7 | 0.7 | 0.9 | 1.3 | 1.2 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

## កំណត់សម្គាល់

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបតំរូចំនួន ៨ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧  ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧: ០០ ដល់ ១១: ០០ព្រឹក និង ២: ០០ ដល់ ៥: ០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្ដែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*